អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

## ការតែងតាំងសហព្រះរាជអាជ្ញាអន្តរជាតិថ្មី

បន្ទាប់ពីមានការចាត់តាំងពីឯកឧត្តម António Guterres អគ្គលេខាធិការអង្គការសហប្រជាជាតិ និងដោយមានការអនុម័តយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះករុណាសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់បានតែងតាំងលោកស្រី Brenda J. HOLLIS (ជនជាតិអាមេរិក) ជាសហព្រះរាជអាជ្ញាអន្តរជាតិថ្មីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចាប់ ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩ នេះតទៅ។

លោកស្រី Hollis ជំនួសលោក Nicholas Koumjian (ជនជាតិអាមេរិក) ដែលបានបញ្ចប់ការតែងតាំងនៅខែមិថុនា កន្លងទៅនេះ។

លោកស្រី Hollis បានទទួលការតែងតាំងជាសហព្រះរាជអាជ្ញាអន្តរជាតិបម្រុង នៅឆ្នាំ២០១៥។ លោកស្រីបានបំពេញការងារជារដ្ឋអាជ្ញានៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនសម្រាប់កិច្ចការដែលនៅសេសសល់ (RSCSL) តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (SCSL) ពីខែកុម្ភៈ ឆ្នាំ២០១០ រហូតដល់ខែសីហា ឆ្នាំ២០១៩ ដែលពីមុននោះ លោកស្រីក៏ធ្លាប់បំពេញការងារជាប្រធានក្រុមមេធាវីផ្នែកជំនុំជម្រះ ដែលទទួលខុសត្រូវដឹកនាំការ ចោទប្រកាន់អតីតប្រធានាធិបតីប្រទេសលីបេរីយ៉ា Charles Taylor ដែរ។

ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០០១ លោកស្រី Hollis ធ្លាប់កាន់មុខតំណែងជាច្រើននៅក្នុងការិយាល័យរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) រួមមាន ជាមេធាវីនាំមុខក្នុងការរៀបចំសំណុំរឿងប្រឆាំងអតីតប្រធានាធិបតីប្រទេសស៊ែប Slobodan Milošević និងជាសហមេធាវីនៅក្នុងរឿងក្តី *Tadić* ជាសំណុំរឿងដំបូងដែលមានការតតាំងក្តីក្នុងតុលាការអន្តរជាតិ ចាប់តាំងពីការជំនុំជម្រះក្តីនៅតុលាការ Nuremberg មក។

លោកស្រី Hollis ធ្លាប់បានបណ្តុះបណ្តាលចៅក្រមព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេតនៅប្រទេសកម្ពុជា ប្រទេសឥណ្ឌូនេស៊ី និងប្រទេសអ៊ីរ៉ាក់។ លោកស្រីក៏ធ្លាប់បានជួយជនរងគ្រោះនៃឧក្រិដ្ឋកម្មអន្តរជាតិនៅប្រទេសកូឡុំប៊ី និងនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ដើម្បីរៀបចំដាក់សារណានានាដែលស្នើសុំឲ្យមានការស៊ើបអង្កេតដោយតុលាការព្រហ្មទណ្ឌអន្តរជាតិផងដែរ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

លោកស្រី Hollis ជាអតីតសមាជិកក្រុមការងារស្ម័គ្រចិត្ត Peace Corps អាមេរិក និងបានចូលនិវត្តន៍ពីកងទ័ពអាកាសអាមេរិកដែលមានឋានន្តរស័ក្តិថ្នាក់វរសេនីយឯក។

***សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖***

លោក នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទចល័ត+៨៥៥(0)១២៤៨៨១៥៦
អ៊ីមែល: neth.pheaktra@eccc.gov.kh